# មេរៀនទី ៩: ព្រះយេស៊ូវបង្រៀននៅក្នុងសាលាប្រជុំ

## លូកា ៤:១៤-២១

**គោលបំណង៖** ព្រះយេស៊ូវជួយដល់មនុស្សដែលរងទុក្ខ។

**ខគម្ពីរចងចាំ៖ យ៉ាកុប ៥:១៣** *"តើមានពួកអ្នករាល់គ្នាណា កើតទុក្ខលំបាកឬទេ ត្រូវឲ្យអ្នកនោះអធិស្ឋាន តើមានអ្នកណាអរសប្បាយឬទេ ត្រូវឲ្យគេច្រៀងសរសើរដល់ព្រះចុះ។"*

**ការថ្វាយបង្គំសំរាប់គ្រូ៖(សូមអានហើយអធិស្ឋានមុនពេលចាប់ផ្ដើមបង្រៀន)**

សូមអានព្រះគម្ពីរ **លូកា ៤:១៨-២១**។ ដែលបានប្រាប់យើងថា ព្រះយេស៊ូវបានអានព្រះគម្ពីរអេសាយ ហើយទ្រង់មានបន្ទូលថា ទ្រង់គឺជាព្រះមេស្ស៊ី ដែលគម្ពីរអេសាយបានពណ៌នា។ តើអ្នកគិតថាមនុស្សទាំងអស់ដែលអង្គុយនៅសាលាប្រជុំនឹងមានប្រតិកម្មដូចម្ដេចនៅពេលបានឮបែបនេះ? មានមនុស្សជាច្រើនមិនសប្បាយចិត្តពេលដែលឮព្រះយេស៊ូវមានបន្ទូលថាទ្រង់ជាព្រះមេស្ស៊ី។ សូមឲ្យយើងបានអធិស្ឋានអរព្រះគុណដល់ព្រះដែលធ្វើឲ្យអ្នកបានជឿលើព្រះយេស៊ូវដែលជាព្រះមេស្ស៊ី។ ហើយសូមអធិស្ឋានឲ្យកូនសិស្សដែលអ្នកនឹងបង្រៀនដូចគ្នា ដើម្បីឲ្យពួកគេជឿលើព្រះយេស៊ូវ ដែលជាព្រះមេស្ស៊ីរបស់ពួកគេផងដែរ។

**ចំរៀង៖** ១. សរសើរព្រះយេស៊ូវ ២. ហូសាណានៅឋានខ្ពស់បំផុត ៣. ពេលព្រះវិញ្ញាណបរិសុទ្ធ

**១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបើក)*

**២. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

### ៣. ល្បែងកំសាន្ត « គូររូបមុខក្រៀមក្រំ »

**សម្ភារៈដែលត្រូវការ៖** បោះពុម្ពក្រដាសដែលមានតែទម្រង់មុខ (សូមមើលនៅទំព័រខាងក្រោម)



១. ពេលកុមារដើរចូលមកក្នុងថ្នាក់រៀន សូមហុចក្រដាសទៅឲ្យពួកគេហើយឲ្យពួកគេគូររូបមុខពួកគេ នៅពេលដែលពួកគេមិនសប្បាយចិត្ត តើមុខរបស់គេមើលទៅយ៉ាងម៉េច?

២. សូមឲ្យកុមារគូររូបលើក្រដាសតែម្ខាងបានហើយ ហើយឲ្យពួកគេទុកក្រដាសម្ខាងទៀត។ (យើងនឹងប្រើក្រដាសម្ខាងទៀតសំរាប់ធ្វើហត្ថកម្ម)

### ៤. ការណែនាំមេរៀន

តើប្អូនធ្លាប់យំដែរឬទេ? ហេតុអ្វីបានជាប្អូនយំ? (ទុកឲ្យកុមារឆ្លើយ) មានពេលជាច្រើនដែលយើងមានអារម្មណ៍ថាសោកសៅ ឬកើតទុក្ខ។ ពេលដែលយើងមានអារម្មណ៍បែបនេះ យើងអាចនឹងគិតថាយើងកំពុងតែនៅឯកា។ ថ្ងៃនេះយើងនឹងរៀនពីព្រះយេស៊ូវ ជាអ្នកដែលដឹងពេលយើងយំដោយសារតែភាពសោកសៅ ឬកើតទុក្ខ ហើយនឹងរបៀបដែលទ្រង់ជួយយើងនៅពេលដែលយើងឈឺចាប់។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ព្រះយេស៊ូវបានធ្វើដំណើរជុំវិញស្រុកភូមិដើម្បីបង្រៀននិងប្រោសមនុស្ស។ មនុស្សជាច្រើនបានឮពីព្រះនាមទ្រង់។ ថ្ងៃមួយពេលព្រះយេស៊ូវយាងទៅសាលាប្រជុំក្នុងស្រុកកំណើតរបស់ទ្រង់ ដែលជាទីក្រុងតូចមួយឈ្មោះណាសា-រ៉ែត។ សាលាប្រជុំប្រៀបដូចជាព្រះវិហារ ជាទីកន្លែងដែលជនជាតិយូដាទៅថ្វាយបង្គំព្រះ។ ប្រជាជននៅទីនោះមានចិត្តរំភើប ដោយសារពួកគេធ្លាប់បានស្គាល់ព្រះយេស៊ូវតាំងពីទ្រង់នៅក្មេង ហើយពួកគេក៏បានឮពីការអស្ចារ្យទាំងប៉ុន្មានដែលទ្រង់បានធ្វើផងដែរ។ ព្រះយេស៊ូវបានក្រោកឡើងក្នុងសាលាប្រជុំ ហើយបើកគម្ពីរទៅក្នុងកណ្ឌគម្ពីរអេសាយ។ ទ្រង់បានអានព្រះបន្ទូលទាំងនេះ។ (សូមបោះពុម្ព និងបង្ហាញខគម្ពីរខាងក្រោម)

**អេសាយ ៦១:១-៣** “ព្រះវិញ្ញាណនៃព្រះអម្ចាស់យេហូវ៉ាទ្រង់សណ្ឋិតលើខ្ញុំ ពីព្រោះព្រះយេហូវ៉ាទ្រង់បានចាក់ប្រេងតាំងខ្ញុំឲ្យផ្សាយដំណឹងល្អដល់មនុស្សទាល់ក្រ ទ្រង់បានចាត់ខ្ញុំឲ្យមកដើម្បីនឹងប្រោសមនុស្សដែលមានចិត្តសង្រេង និងប្រកាសប្រាប់ពីសេចក្តីប្រោសលោះដល់ពួកឈ្លើយ ហើយពីការដោះលែងដល់ពួកអ្នកដែលជាប់ចំណង។ ព្រមទាំងប្រកាសប្រាប់ពីឆ្នាំដែលព្រះយេហូវ៉ាទ្រង់សព្វព្រះហឫទ័យ និងពីថ្ងៃដែលព្រះនៃយើងខ្ញុំនឹងសងសឹកផង ហើយឲ្យកំសាន្តចិត្តនៃអស់អ្នកណាដែលសោយសោក។ នឹងចែកឲ្យដល់ពួកអ្នកដែលសោយសោក នៅក្រុងស៊ីយ៉ូនបានភួងលំអជំនួសផេះ ហើយប្រេងនៃសេចក្តីអំណរជំនួសសេចក្តីសោកសៅ ព្រមទាំងអាវពាក់នៃសេចក្តីសរសើរ ជំនួសទុក្ខធ្ងន់ដែលគ្របសង្កត់ ដើម្បីឲ្យគេបានហៅថាជាដើមឈើនៃសេចក្តីសុចរិត គឺជាដើមដែលព្រះយេហូវ៉ាបានដាំមានប្រយោជន៍ឲ្យទ្រង់បានថ្កើងឡើង។”

បន្ទាប់ពីព្រះយេស៊ូវអានចប់មនុស្សទាំងអស់រង់ចាំមើល ថាព្រះអង្គនឹងមានបន្ទូលអ្វីទៀត **លូកា៤:២១** ប្រាប់យើងថា “ ទ្រង់ចាប់តាំងមានព្រះបន្ទូលទៅគេថា នៅថ្ងៃនេះបទគម្ពីរបានសំរេចនៅត្រចៀកអ្នករាល់គ្នាហើយ។”

ពេលដែលមនុស្សបានឮបែបនេះ ពួកគេមានការភ្ញាក់ផ្អើល។ ព្រះយេស៊ូវមានបន្ទូលថា ទ្រង់គឺជាម្នាក់ដែលបានសន្យា ហើយបានសរសេរនៅក្នុងគម្ពីរអេសាយប្រហែលជា៧០០ឆ្នាំមុន។ ទ្រង់គឺជាព្រះអង្គសង្គ្រោះ ព្រះមេស្ស៊ីជាអ្នកដែលប្រោសមនុស្សខ្វាក់ និងរំដោះអ្នកដែលត្រូវគេជិះជាន់ឲ្យរួច។ ទ្រង់គឺជាអ្នកដែលជួយដល់អ្នកដែលយំសោកដោយសារតែភាពសោកសៅ និងមានទុក្ខព្រួយ។

ព្រះគម្ពីរបានប្រាប់យើងថាពេលដែលព្រះយេស៊ូវរស់នៅលើផែនដី ទ្រង់បានយំជាមួយសម្លាញ់របស់ទ្រង់ ពេលដែលពួកគេសោកសង្រេង។ ពេលដែលមាននរណាម្នាក់យំជាមួយយើង យើងមានអារម្មណ៍ថាដូចជាត្រូវបានលួងលោម ហើយភាពសោកសៅបន្តិចបន្តួចរបស់យើងក៏រសាយបាត់ទៅ។ ព្រះយេស៊ូវទ្រង់ជ្រាបនៅពេលដែលយើងកើតទុក្ខ។ ទ្រង់ជួយដល់មនុស្សដែលមានទុក្ខព្រួយ ហើយព្រះអង្គនឹងកំសាន្តចិត្តហើយផ្តល់នូវសន្តិភាពដល់យើង។

## ៦. សំនួរពិភាក្សា

១. តើកន្លែងដែលជនជាតិយូដាទៅថ្វាយបង្គំឈ្មោះអ្វី? *សាលាប្រជុំ*

២. តើព្រះគម្ពីរអ្វីដែលព្រះយេស៊ូវយកមកអាននៅក្នុងសាលាប្រជុំ? *ព្រះគម្ពីរអេសាយ*

៣. តើហេតុអ្វីបានជាមនុស្សមានការភ្ញាក់ផ្អើល? *ព្រះយេស៊ូវមានបន្ទូលថា ទ្រង់គឺជាព្រះមេស្ស៊ី ដែលពិពណ៌នានៅក្នុងគម្ពីរអេសាយ*

៤. តើអ្នកអាចធ្វើអ្វីបានខ្លះពេលដែលអ្នកយំ? *ទូលសូមព្រះយេស៊ូវឲ្យទ្រង់បានកំសាន្តចិត្តយើង ត្រូវការអ្នកណាម្នាក់អោប ឬលួងលោមអ្នក ឬក៏ត្រូវការការនៅជិតម្តាយរបស់អ្នក*

## ៧. ល្បែងកំសាន្ត « ឆ្លងកាត់ឧបសគ្គ »



**សម្ភារៈដែលត្រូវការ៖** កៅអី តុ ក្រមា ធុងទឹក ដុំថ្ម(តាមស្ថានភាពទីតាំង)

១. យើងបែងចែកកុមារជា២ក្រុម

២. ក្រុមនីមួយត្រូវរើសម្នាក់ៗមកដើម្បី ចងរុំភ្នែករបស់គេជាមួយនឹងក្រមា

៣. យើងត្រូវយកសម្ភារៈមកដាក់ពាសពេញថ្នាក់រៀនធ្វើជាឧបសគ្គ

៤. បន្ទាប់មកឲ្យកុមារដែលត្រូវគេចង់ភ្នែកនោះ ដើរឆ្លងកាត់ឧបសគ្គទាំងឡាយដោយសមាជិកក្រុមនីមួយៗត្រូវស្រែកប្រាប់អ្នកដែលត្រូវបិទភ្នែកនោះថា (ត្រូវហើយ, ដើរវៀង ,ដើរកន្លង ,លូន ទៅឆ្វេង ទៅស្តាំ ទៅមុខ... )។

សូមពន្យល់កុមារថា ការជួយគ្នាឲ្យឆ្លងពីទីតាំងម្ខាងទៅទីតាំងម្ខាងទៀតនៅក្នុងថ្នាក់ ដោយមិនជាន់នៅលើឧបសគ្គណាមួយនោះ នឹងជួយឲ្យយើងបានសម្រេចនូវគោលដៅយ៉ាងពិតប្រាកដ។

## ៨. ខគម្ពីរចងចាំ យ៉ាកុប ៥:១៣

## ៩. ហត្ថកម្ម «គូររូបមុខរីករាយ »



១. ប្រាប់កុមារយកមុខក្រៀមក្រំដែលគេបានគូរនៅពេលចាប់ផ្តើមរៀនចេញមក

២. គ្រូពន្យល់កុមារ៖ យើងបានរៀនរួចមកហើយថា នៅពេលដែលយើង សោកសៅ ឬកើតទុក្ខ ព្រះយេស៊ូវនឹងកំសាន្តចិត្តយើង។

៣. ប្រាប់កុមារឲ្យត្រឡប់ក្រដាសរបស់ពួកគេទៅខាងខ្នង(ខាងទំពរទទេរ) ដោយឲ្យគូរនូវទឹកមុខរបស់ពួកគេថានឹងទៅជាបែបណា នៅពេលដែលព្រះយេស៊ូវបានកំសាន្តចិត្តពួកគេ។

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបិទ)*





អេសាយ ៦១:១-៣ “ព្រះវិញ្ញាណនៃព្រះអម្ចាស់យេហូវ៉ា ទ្រង់សណ្ឋិតលើខ្ញុំ ពីព្រោះព្រះយេហូវ៉ាទ្រង់បានចាក់ប្រេងតាំងខ្ញុំឲ្យផ្សាយដំណឹងល្អដល់មនុស្ស ទាល់ក្រ ទ្រង់បានចាត់ខ្ញុំឲ្យមក ដើម្បីនឹងប្រោសមនុស្សដែលមានចិត្តសង្រេង និងប្រកាសប្រាប់ពីសេចក្តីប្រោសលោះដល់ពួកឈ្លើយ ហើយពីការដោះលែងដល់ពួកអ្នកដែលជាប់ចំណង។ ព្រមទាំងប្រកាសប្រាប់ពីឆ្នាំ ដែលព្រះយេហូវ៉ាទ្រង់សព្វព្រះហឫទ័យ និងពីថ្ងៃ ដែលព្រះនៃយើងខ្ញុំនឹងសងសឹកផង ហើយឲ្យកំសាន្តចិត្តនៃអស់អ្នកណាដែលសោយសោក។ នឹងចែកឲ្យដល់ពួកអ្នកដែលសោយសោក នៅក្រុងស៊ីយ៉ូនបានភួងលំអជំនួសផេះ ហើយប្រេងនៃសេចក្តីអំណរជំនួសសេចក្តីសោកសៅ ព្រមទាំងអាវពាក់នៃសេចក្តីសរសើរ ជំនួសទុក្ខធ្ងន់ដែលគ្របសង្កត់ ដើម្បីឲ្យគេបានហៅថា ជាដើមឈើនៃសេចក្តីសុចរិត គឺជាដើមដែលព្រះយេហូវ៉ាបានដាំ មានប្រយោជន៍ឲ្យទ្រង់បានថ្កើងឡើង។”